# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## «ការចូលសវនាការសាលាឧទ្ធរណ៍ របស់បុគ្គលិក និងអតីតបុគ្គលិក សមាគមអាដហុក នៅរសៀល ថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០២២»

សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា ហៅកាត់ថា "**អាដហុក**" មានកិត្តិយសសូមជូនដំណឹងដល់សាធារណជន អង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ ស្ថានទូតអន្តរជាតិ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិទាំងអស់ជ្រាបថា នៅរសៀលម៉ោង២ ថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០២២ ខាងមុខនេះ នៅបន្ទប់សាលសវនាការលេខ២ បន្ទាប់ពីបានពន្យាពេលសវនាការ កាលពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០២២ បុគ្គលិកសមាគមអាដហុកចំនួន ០៣ (បី) រូប រួមមានលោក **នី សុខា** លោក **យី សុខសាន្ត** និងលោកស្រី **លឹម មុន្នី** និងអតីតបុគ្គលិកអាដហុកចំនួន ០២ (ពីរ) រូបទៀតគឺលោក **ណៃ វង់ដា** និងលោក **នី ចរិយា** នឹងសម្រេចចូលសវនាការសាលាឧទ្ធរណ៍ភ្នំពេញ តាមដីការកោះចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២២ របស់មហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីជំនុំជំរះ ពីបទ "**អំពើសូកប៉ាន់សាក្សី**" ។

**សូមបញ្ជាក់ថា** កាលពីថ្ងៃទី ២៣ ខែតុលា ឆ្នាំ២០១៨ អ្នកទាំង៥ (ប្រាំ) រូប បានដាក់ពាក្យបណ្តឹងឧទ្ធរណ៍ដោយមិនសុខចិត្តទៅនឹងសាលក្រមព្រហ្មទណ្ឌលេខ ៧៣០ ក្រវ"ច" ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេចផ្តន្ទាទោសពួកគេដាក់ពន្ធនាគារ ម្នាក់ៗកំណត់០៥ឆ្នាំ ដោយត្រូវអនុវត្តក្នុងពន្ធនាគាររយៈពេល១៤ (ដប់បួន) ខែ និងសល់ប៉ុន្មានព្យួរ ពីបទ "**សូកប៉ាន់សាក្សី**" ហើយដែលពួកគាត់យល់ថា ការសម្រេចនេះមិនផ្តល់ភាពយុត្តិធម៌ និងបានធ្វើឲ្យប៉ះពាល់ដល់សិទ្ធិ សេរីភាព ព្រមទាំងកិត្តិយសរបស់ពួកគាត់យ៉ាងខ្លាំងទៀតផង ។ អ្នកទាំងប្រាំ ត្រូវបានចាប់ខ្លួនដោយអង្គភាពប្រឆាំងអំពើពុករលួយ កាលពីថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០១៦ ពីបទ "**សូកប៉ាន់សាក្សី**" តាមមាត្រា ៥៤៨ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ហើយត្រូវបានបញ្ជូនទៅឃុំខ្លួននៅពន្ធនាគាព្រៃស "ម១" និង ម២ នៅថ្ងៃទី ០១ ខែឧសភា ឆ្នាំ២០១៦ រហូតដល់ថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០១៧ ។

ដូច្នេះ ដើម្បីបន្តការតាមដានដំណើរការសាវនាកាខាងលើនេះ យើងខ្ញុំសូមគោរពអញ្ជើញសាធារណជន អង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ តំណាងស្ថានទូត អ្នកសារព័ត៌មានជាតិ និងអន្តរជាតិទាំងអស់ ចូលរួមកុំបីខាន ។ សូមអរគុណ!

**សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងះ**

**១. លោក ស៊ឹង សែនករុណា** ៖ (៨៥៥)៨៦ ៣៤២ ៦៦៦

**២. លោក ភិន សារ៉េ** ៖ (៨៥៥)៨៦ ៣៨១ ៦៦៦